**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ: ៤៥២
ចុះថ្ងៃទី២៥ ខែវិច្ឆកា ឆ្នាំ ២០០៣
**<u>សាលដីកា</u>**
លេខ: ១៦៣
ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៣
ខែសីហា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក ................ ជាចៅក្រម
៥-លោក ................ ជាចៅក្រមរបាយការណ៍

**<u>ក្រឡាបញ្ជី</u>**
-អ្នកស្រី ................

**<u>តំណាងមហាអយ្យការ</u>**
-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា ១១០(គ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៩៤ ចុះថ្ងៃទី១៨ ខែកុម្ភះ ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍រវាង ។

ដើមចោទឈ្មោះ ឧយ( ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៦៧ឆ្នាំ ជាតិខ្មែរ មុខរបនិវត្តន៍ជន មានទីលំនៅភូមិតាព្រហ្ម ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ឪពុកឈ្មោះឌុច យ៉ា(ស) ម្តាយឈ្មោះតូច សុខ (ស) ប្រពន្ធឈ្មោះ សំ ប៉ិច មានកូន០៦នាក់ ។

ចុងចម្លើយឈ្មោះ លក(ជាម្ចាស់បណ្តឹងសាទុក្ខ )ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរមុខរបរ ប៉ះកង់ ទីលំនៅភូមិតាព្រហ្ម ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ឪពុកលន់ ចក់ (ស) ម្តាយឈ្មោះហ៊ុន ស៊ុត (ស) ប្រពន្ធឈ្មោះ គឹម ឡាង មានកូន០៧នាក់ ។

**<u>កម្មវត្ថុបណ្តឹង</u>**: ប្តឹងទាមទារប្រាក់ .

បានឃើញបណ្តឹងសាទុក្ខលេខ ៣៣៥ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះលកប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១១០(គ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៥២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់តុលាការកំពូល។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០២ របស់ដើមចោទបញ្ជាក់ថា ខ្លួនប្តឹងទាមទារប្រាក់ចំនួន ៣.៣០០ដុល្លាអាមេរិក ពីឈ្មោះលកនិងនាង គឹម ឡាង ដោយសំអាងហេតុថា ឈ្មោះលកនិងនាងគឹម ឡាង បានខ្ចីប្រាក់ខ្លួន តែពុំទាន់បានសងនៅឡើយ ។

តាមពាក្យបណ្តឹងតបផ្ទុះថ្ងៃទី០២-០៨-២០០២ របស់ចុងចម្លើយឈ្មោះលកនិងនាងគឹម ឡាង សុំប្តឹងតបទៅនឹងបណ្តឹងទាមទារប្រាក់របស់ឈ្មោះ ឧយ ដោយសំអាងហេតុថា ឈ្មោះ ឧយ បាន ទាមទារប្រាក់ពីខ្លួនច្រើនហួសប្រមាណលើប្រាក់បំណុល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១០០(ព) ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០២របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងដើមចោទឈ្មោះឧយ ចុះថ្ងៃទី១០-៧-២០០២ ទុកជាត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់ ។

២-បង្គាប់ឱ្យចុងចម្លើយឈ្មោះលន់ គឿន និងប្រពន្ធឈ្មោះគឹម ឡាង សងប្រាក់ដើមចំនួន ៣.៣០០ដុល្លាអាមេរិក ទៅដើមចោទឈ្មោះឧយ នៅពេលសាលក្រមចូលជាស្ថាពរ និងបង្គាប់ឱ្យបង់ការប្រាក់ ៥ភាគរយ ក្នុង០១ឆ្នាំ លើទឹកប្រាក់ចំនួន ៣៣០០ដុល្លាអាមេរិក គិតពីថ្ងៃធ្វើលិខិតជំពាក់ប្រាក់ថ្ងៃទី០១-១១-២០០១ រហូតដល់ថ្ងៃសងគ្រប់ ហើយឱ្យចុងចម្លើយសងសំណងសោហ៊ុយចុះឡើងខាតបង់ពេលវេលា ជាប្រាក់ចំនួន ៥០ដុល្លាអាមេរិក ការទាមទារលើសពីនេះត្រូវលើកចោល ។

- ក្នុងករណីចុងចម្លើយគ្មានប្រាក់សងត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង តែបើរឹងរូសពុំព្រមសងត្រូវដាក់គុកបង្ខំលើរូបកាយដើម្បីឱ្យសងប្រាក់ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧.០០០៛ ដែលដើមចោទបានបង់ តែបង្គាប់ឱ្យចុងចម្លើយ សងទៅដើមចោទវិញ និងបង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រជាប្រាក់ចំនួន៣៣ដុល្លាអាមេរិក ប្រាក់នេះសម្រាប់បង់ចូលថវិការដ្ឋ និងហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស ។

៤-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចុងចម្លើយ ។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៣៥ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះលកប្តឹង មិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១០០(ព) ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០២ របស់តុលាការខេត្ត កណ្តាល ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៨៣ (គ) ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៣ របស់សាលា ឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៦-១២-២០០២ របស់ឈ្មោះលកទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១០០(ព)ចុះថ្ងៃទី១៧-១០-២០០២ របស់តុលាការខេត្តកណ្តាល ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ដែលចុងចម្លើយបានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ២៥៥០៛ ង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ច ប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាផ្ជាធរតុលាការ៥.០០០៛ ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ ក៏បាំងមុខចុងម្លើយ ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងទាស់លេខ ៦៤ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៣ របស់ឈ្មោះលកប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៨៣ (គ)ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៣ របស់សាលា ឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១១០(គ) ចុះថ្ងៃទី១០-៧-២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងទាស់ចុះថ្ងៃទី៣០-៥-២០០៣ របស់ឈ្មោះលន់ គឿន ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ ៨៣(គ) ចុះថ្ងៃទី០៦-៥-២០០៣ របស់ សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ។

បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៣៥ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះលកប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១១០(គ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៣ របស់សាលា ឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

បានឃើញសារណាការពារចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះលកនិងគីម ឡាង ។

បានឃើញសារណាតបចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះឌុច យ៉ាន ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីកាសាលាឧទ្ធរណ៍ ដែលសម្រេច សេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះលកនាពេលសវនាការថា : បានជាខ្លួនប្តឹងសាទុក្ខមកតុលាការ កំពូលនេះ មកពីសាលាឧទ្ធរណ៍កាត់ក្តីមិនត្រឹមត្រូវ ពីព្រោះខ្លួន និងប្រពន្ធខ្លួនបានខ្ចីលុយពីប្រពន្ធគាត់ចំនួន ១៩០០ដុល្លាអាមេរិកទេ ចំពោះប្រាក់៣៣០០ដុល្លានេះ គឺប្រាក់ដើមបូកនឹងការប្រាក់ ចំនួនប្រាក់ដែលខ្លួនបាន ជំពាក់គាត់ពិតប្រាកដនោះតែ

ចំនួន១៩០០ដុល្លាអាមេរិក ការខ្ចីប្រាក់នេះមានចំនួន៧លើក ។ លើកទី១ ចំនួន ៥០០ដុល្លា លើកទី២ ចំនួន១០០ដុល្លា លើកទី៣ ចំនួន១០០ដុល្លា លើកទី៤ ចំនួន៥០០ដុល្លា លើកទី៥ ចំនួន៥០០ដុល្លា លើកទី៦ ចំនួន១០០ដុល្លា និងលើកទី៧ ចំនួន ១០០ដុល្លា ស្រាប់តែនៅក្នុងពាក្យបណ្តឹងរបស់លោកពូ ឌយ ដាក់ថា ខ្លួន និងប្រពន្ធជំពាក់ប្រាក់ចំនួន៣៣០០ដុល្លាទៅវិញ ។ ហេតុនេះ សូម លោកប្រធានតុលាការកំពូល មេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

បានស្តាប់ចម្លើយរបស់ឈ្មោះឌយ នាងពេលសវនាការថា : ខ្លួនសូមជំរាបជូនឯកឧត្តមប្រធាន មេត្តាជ្រាបថា : បំណុលទាំងអស់ចំនួន ៣៧០០ដុល្លា ជាប្រាក់ដើមសុទ្ធ អត់មានបូកការប្រាក់ ចុងចម្លើយក៏ ទទួលស្គាល់បំណុលនេះ ការខ្ចីលុយនេះ ខ្លួនអត់ដឹងទេ ព្រោះចុងចម្លើយទៅខ្ចីប្រពន្ធខ្លួន ខ្លួនធ្លាក់ខ្លួនឈឺធ្ងន់ ទើបប្រាប់ខ្លួនថា ចុងចម្លើយបានខ្ចីលុយអស់ហើយ ទៅទារផង ខ្លួនសួរថាប៉ុន្មាន គាត់ឆ្លើយថា នាងគីមឡាង ថា ប៉ុណ្ណា ប៉ុណ្ណោះហើយ ខ្លួនក៏ទៅសួរនាងគីម ឡាង ថា នាងជំពាក់លុយមីងឯងប៉ុន្មានដែរ ចុងចម្លើយ ឆ្លើយថា ៣៧០០ដុល្លាពូ។ ខ្លួនក៏បញ្ជាក់ថា ៣៧០០ដុល្លានេះជាប្រាក់ដើមសុទ្ធ នាងឆ្លើយថា ចា ខ្លួនក៏ធ្វើ លិខិតកិច្ចសន្យាចុះថ្ងៃទី០១-១១-២០០១ ហើយក្នុងប្រាក់ដើមចំនួន៣៧០០ដុល្លានេះ ចុងចម្លើយបានសង មកខ្លួនបានចំនួន៥០០ដុល្លារួចហើយ នៅជំពាក់ចំនួន៣៣០០ដុល្លាពិតប្រាកដមែន ។ហេតុដូច្នេះ សូមប្រធាន មេត្តាសម្រេចឱ្យចុងចម្លើយសងប្រាក់មកខ្លួនគ្រប់ចំនួន ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចំលើយគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៣៥ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះ លភធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា តាមកំណត់ហេតុចុះថ្ងៃទី២៩-៣-២០០២ នៅសាលាឃុំព្រែកឯង និង តាមកិច្ចសន្យាជំពាក់ប្រាក់ចុះថ្ងៃទី០១-១១-២០០១ បញ្ជាក់ថា ចុងចម្លើយឈ្មោះ លភនិងនាងគីម ឡាង ពិតជាជំពាក់ប្រាក់ដើមចោទចំនួន៣៣០០ដុល្លាអាមេរិកប្រាកដមែន ហើយចុងចម្លើយមិនទាន់បានអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនតាមមាត្រា ២២.២៩ និង ៣០ នៃក្រឹត្យច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យានៅឡើយទេ ។

- យល់ឃើញថា ចុងចម្លើយបានលើកឡើងនៅក្នុងសារណារបស់ខ្លួនចុះថ្ងៃទី២១-១២-២០០៣ថា ខ្លួនបានខ្ចីប្រាក់ពីឈ្មោះឌយ តែចំនួន ១៩០០ដុល្លា និងខ្ចីជាច្រើនដង ហើយមានការប្រាក់ខុសៗគ្នា និងបានសងការប្រាក់ឱ្យឈ្មោះ ឌយ សរុបចំនួន៤២០០ដុល្លានោះ ពុំមានភស្តុតាងណាបញ្ជាក់អំពីហេតុ ការណ៍នេះឡើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១១០ (គ) ចុះថ្ងៃទី១០ កក្កដា ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៣៥ ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះលភទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនិងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ១០ (គ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលដើមចោទ បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛

-បង្គាប់ឱ្យចុងចម្លើយសងប្រាក់១៩.០០០រៀល ទៅដើមចោទវិញ

និងបង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តកណ្តាល

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០៤ ។